***ឧបសម្ពន្ធ៖ សំនួរ និងចម្លើយ***

# សិក្ខាសាលាស្តីពី
# ការណែនាំការរៀបចំសំណើសុំផ្តល់មូលនិធិជំនួយឥតសំណង
# ដល់គម្រោងនវានុវត្តន៍ប្រែប្រួលអាកាសធាតុ

**រាជធានីភ្នំពេញ ថ្ងៃសុក្រ ២កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩**

**សំនួរ:** ខ្ញុំមានការចាប់អារម្មណ៍ចំពោះការលើកឡើងស្តីពីពាក្យ "ផ្លាស់ប្តូរ ទម្លាប់ ឥរិយាបទចាស់" តើការផ្លាស់ប្តូរនេះ សំដៅទៅលើទម្លាប់ ឥរិយាបទចាស់ ដែលយើងតែងតែធ្វើដូចរាល់ដង ឬ សំដៅទៅលើសកម្មភាពសម្រាប់អនុវត្តផងដែរ ?

**ចម្លើយ:** ការផ្លាស់ប្តូរជាតម្លៃបន្ថែមមួយ (Value Added) ទៅលើគម្រោងសំណើ។ វាអាចលើសពីតំលៃជាលុយ វាសំដៅលើគំនិតច្នៃប្រឌិត និងប្រសិទ្ធភាពការងារ។ ខ្ញុំសូមឱ្យជាឧទាហរណ៍មួយ នៅពេលដែលយើងធ្វើផ្លូវ យើងមិនបានគិតគូដល់ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដែលយើងចំណាយប្រហែល ១០០,០០០ដុល្លារអាមេរិកសម្រាប់ការសាងសង់ផ្លូវរួចរាល់ តែផ្លូវបែបនេះអាចនឹងខូចទៅវិញត្រឹមតែមួយឆ្នាំក្រោយមក។ **ការផ្លាស់ប្តូរនៅត្រង់**នេះគឺមានន័យថា យើងត្រូវប្រែក្លាយពីការកសាងផ្លូវតាមទម្លាប់ចាស់ៗ (មិនគិតគូពីការប្រែប្រួលអាកាសធាតុ) ទៅជាការកសាងផ្លូវដោយគិតពីការប្រែប្រួលអាកាសធាតុ។ ការផ្លាស់ប្តូរនេះគឺមានន័យថាផ្លូវនេះបានគិតគូបញ្ចូលគំនិត "**ការគិតគូរពីការប្រែប្រួលអាកាសធាតុ**" ដូចនេះផ្លូវនេះមានលក្ខណៈធន់នឹងការប្រួលអាកាសធាតុ អាចប្រើប្រាស់បានយូរឆ្នាំ។ យើងផ្លាស់ប្តូរពីការធ្វើផ្លូវបែបធម្មតា មកជាការធ្វើផ្លូវដែលគិតគូពីទឹកជំនន់ គ្រោះរាំងស្ងួត បច្ចេកទេសនៃការរៀបចំ កសាងផ្លូវ ការដាក់លូទឹក ។ល។ នៅក្នុងឯកសារគោលការណ៍ណែនាំយើង មានការពិពណ៌នាពីការផ្លាស់ប្តូរ/នវានុវត្តន៍ (Innovation)នេះ ។ នវានុវត្តន៍ អាចជាការគិតគូរបែបវិទ្យាសាស្រ្ត និងវិធីសាស្រ្តថ្មីៗ ។ ពេលខ្លះយើងអាចសិក្សាពីករណីសិក្សាមួយចំនួនដែលមិនទាន់កើតមាននៅក្នុងប្រទេសកម្ពុជា ក្នុងបរិបទភាពធន់នឹងអាកាសធាតុ មកដាក់បញ្ចូលក្នុងសកម្មភាពគំរោងរបស់យើង យកបច្ចេកទេស/បច្ចេកវិទ្យាថ្មី មកបំពេញបន្ថែមនៅចំនុចខ្វះខាត ឬសកម្មភាពដែលយើងតែងតែធ្វើដដែលៗ។

**សំនួរៈ** នៅតាមក្រសួង ស្ថាប័នីមួយៗ មានផ្នែក ឫនាយកដ្ឋានច្រើន តើអាចទៅរួចទេដែលផ្នែក ឫនាយកដ្ឋាននីមួយៗ ដាក់សំណើរគម្រោង ឧទាហរណ៍ ក្រសួងខ្ញុំមាន ៣នាយកដ្ឋាន ហើយ៣នាយកដ្ឋាននេះដាក់សំណើគម្រោងមកទាំងបីផ្សេងគ្នានោះ?
**ចម្លើយៈ** វាអាស្រ័យទៅលើក្រសួង ឫនាយកដ្ឋានទាំងនោះ យើងមិនមានការកំណត់លក្ខខណ្ឌថាតើក្រសួងមួយ ឫនាយកដ្ឋាន មួយអាចដាក់សំណើរគម្រោងតែមួយ ឫច្រើននោះទេ ។ ជាបទពិសោធន៍ដែលយើងបានរៀនសូត្រពី GCF គេមានលុយច្រើន គម្រោងណាមកមុន គេពិនិត្យមុន ក្នុងនោះ គេក៏គិតគូរពិចារណាពីកត្តាភូមិសាស្ត្រ/ទីតាំងរបស់គំរោង ដូចនេះ យើងអាចនឹងពិចារណាករណីនេះផងដែរ ក្រសួងឫស្ថាបន័មួយ ប្រហែលជាមិនអាចជាប់នាយកដ្ឋានឫស្ថាប័នច្រើនឡើយ។

**សំនួរៈ** តាមការធ្វើបទបង្ហាញ សំណើគម្រោងនេះនឹងបន្សុីជាមួយផែនការយុទ្ធសាស្ត្រ CCCSP តែក្នុងផែនការយុទ្ធសាស្ត្រនេះ មានគោលដៅ សកម្មភាពច្រើនណាស់ ឧទាហរណ៍ ការកសាងសមត្ថភាព ការសិក្សាស្រាវជ្រាវ ។ល។ អញ្ចឹងសំណើគម្រោងនេះ ផ្តល់អាទិភាពឫផ្តោតទៅលើការកសាងសមត្ថភាពច្រើនជាង ឫការសិក្សាស្រាវជ្រាវច្រើនជាង ឫផ្នែកណាមួយជាក់លាក់?
**ចម្លើយៈ** ទាក់ទងប្រធានបទ គឺមានលក្ខណៈទូលាយ អាចជាគម្រោងផ្តោតលើការងារបន្សាំការប្រែប្រួលអាកាសធាតុ ឫអាចជាការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ អាចបន្សុីជាមួយផែនការយុទ្ធសាស្ត្រតាមវិស័យ ឫអនុវិស័យក៏បានដែរ។ ពិតណាស់ គម្រោងសំណើរនេះ ផ្តោតការយកចិត្តទុកលើផែនការយុទ្ធសាស្ត្រ CCCSP តែយើងមិនកំណត់ទេ យើងចង់ឃើញសំណើរគម្រោងមានលក្ខណៈពីក្រោមឡើងលើ អញ្ចឹងវាអាស្រ័យទៅលើការសិក្សាពីអង្គការសង្គមសុីវិល ក្រសួង វិស័យឯកជន ជាអ្នកកំណត់ប្រធាបបទ/សកម្មភាពដើម្បីអោយបន្សុីជាមួយ CCCSP ។ យើងមានការរំពឹងទុកថា សំណើគម្រោងលើកនេះ មានការផ្តោតទៅលើអ្វីដែលជាតម្រូវការពីសហគមន៍ ហើយសកម្មភាពអាចជាផ្នែកនៃការកសាងសមត្ថភាពការសិក្សាស្រាវជ្រាវ ។ល។

**សំនួរៈ** នៅក្នុងនិតីវិធី ឫដំណើរការពិនិត្យសំណើរគម្រោង មានការកំណត់/តម្រូវឱ្យរៀបចំរបាយការណ៍ត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន និងសង្គម មុននឹងរៀបចំគម្រោងពេញលេញ នេះមានន័យថាថវិកចំណាយនេះ ខាងCCCA ជាអ្នកគាំទ្រ ឫយ៉ាងណា? សូមជួយបញ្ជាក់ផង?
**ចម្លើយៈ** ការរៀបចំរបាយការណ៍ត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន និងសង្គម នេះ វាអាស្រ័យទៅនឹងទំហំនៃផលប៉ះពាល់របស់គម្រោង និងភាពចាំបាច់តែប៉ុណ្ណោះ ។ ការសិក្សាពីផលប៉ះពាល់បរិស្ថាន និងសង្គមនេះមិនមែនជាការសិក្សាពេញលេញនោះទេ តែយើងអាចរៀបចំជាកម្រងបញ្ជីរសំនួរសំខាន់ៗ ដែលសិក្សាដោយមន្ត្រីគម្រោង និងអ្នកពាក់ពន្ធ័តែប៉ុណ្ណោះ ដើម្បីធានាថាគម្រោងដែលនឹងអនុវត្តនោះ មានផលប៉ះ

ពាល់តិចតួចដល់សង្គម និងបរិស្ថាន។ ប្រសិនបើលទ្ធផលនៃការសិក្សានេះ មានភាពធ្ងន់ធ្ងរ ក្រុមការងារនឹងពិភាក្សាជាមួយអ្នកដាក់សំណើ និងមានវិធានការណ៍បន្ថែម ។ សម្រាប់ថវិកា៥.០០០ ដុល្លារអាមេរិកនោះ អ្នកដាក់សំណើអាចស្នើដាក់ជាមុនក្នុងឯកសារទស្សនៈទាន និងបញ្ជាក់ពីគោលដៅ ក្នុងការប្រើប្រាស់ថវិកានេះ ឧទាហរណ៍ ថវិកាសម្រាប់ការកសាងគម្រោង ពេញលេញ ឬធ្វើការសិក្សាបន្ថែមណាមួយ ។ល។

**សំនួរៈ** បើសិនអង្គការ ឬស្ថាបន័មួយបាន និងកំពុងតែអនុវត្តគម្រោងការប្រែប្រួលអាកាសធាតុស្រាប់ តែមានការខ្វះខាតថវិកាសម្រាប់អនុវត្តបន្ត ឬ មានផ្នែកណាមួយនោះ (ដែលមានស្រាប់ ឬថ្មី)ត្រូវការថវិកាបន្ថែម តើគម្រោងប្រភេទនេះ ជាមានលទ្ធភាពស្នើសុំថវិកាដែរឬទេ?
**ចម្លើយៈ** ដូចបានបញ្ជាក់ហើយថា គម្រោងនេះ ផ្តោតទៅលើនវានុវត្តន៍ការប្រែប្រួលអាកាសធាតុ ដូច្នេះរាល់សំណើគម្រោងដែលបានដាក់បញ្ចូលគំនិតផ្តួចផ្តើម បច្ចេកទេសថ្មីៗណាមួយ សុទ្ធតែជាអាទិភាព។សម្រាប់សំណើថវិកានេះ ។ សម្រាប់គម្រោងដែលកំពុងអនុវត្តណាដែលមានលក្ខណៈនវានុវត្តន៍ឬគំនិតថ្មី អាចនៅតែមានអាទិភាព សំខាន់ថាតើតំរូវការបន្ថែមនោះជាអ្វី អាចជាតម្រូវការបច្ចេកទេស ឬថវិកា ដើម្បីអនុវត្តបន្ត ។ ក្នុងករណីនេះ ក្រុមការងារនឹងមានការសិក្សា និង ពិនិត្យលើសំណើគម្រោងបន្ថែមទៀត ។

**សំនួរៈ** តើសំណើគម្រោងស្តីពីការរៀបចំគោលនយោបាយសម្រាប់វិស័យជាក់លាក់ទៅលើការប្រែប្រួលអាកាសធាតុ ឧទាហរណ៍ គោលនយោបាយកសិកម្ម និងការប្រែប្រួលអាកាសធាតុ អាចសមស្របជាមួយលក្ខខណ្ឌសំណើគម្រោងនេះទេ?
**ចម្លើយៈ** ការរៀបចំគោលនយោបាយដាច់ដោយឡែក ដែលមិនមានការដាក់បញ្ចូលនវានុវត្តន៏ការប្រែប្រួលអាកាសធាតុណាមួយ វាមានការលំបាកសម្រាប់ការវាស់វែង និង ពិនិត្យមើលពីឥទ្ធិពលរបស់គម្រោង ក្នុងរយៈពេលខ្លីបែបនេះ ។ ដូច្នេះ អ្នកដាក់សំណើ គួរពិចារណាគម្រោងណាមួយដែលមានលក្ខណៈជាក់លាក់ និងអាចសំរេចទៅបានក្នុងរយៈពេលខ្លីសមរម្យបែបនេះ ។

**សំនួរៈ** បច្ចុប្បន្ននេះ យើងបានរៀបចំគម្រោងមួយ ដែលកែច្នៃថង់ផ្លាស្ទិក អោយទៅជាដុំឥដ្ឋ ។ យើងបានរៀបចំការសិក្សា ការពិសោធន៏នេះរួចរាល់ហើយ ប៉ុន្តែយើងមិនទាន់ថវិកាគ្រប់គ្រាន់ដើម្បីអោយគម្រោងនេះចេញជារូបរាងនៅឡើយទេ ។ តើគម្រោងប្រភេទនេះ សមស្របជាមួយលក្ខខណ្ឌសំណើគម្រោងនេះដែរទេ?
**ចម្លើយៈ** គម្រោងសំណើណាក៏ដោយ សុទ្ធតែមានអាទិភាព ដោយគោរពតាមលក្ខខណ្ឌដែលសំណើគម្រោង និងគោលការណ៏ណែនាំបានចែង ។ គម្រោងទាំងអស់ ត្រូវតែចូលរួមចំណែកដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ អាចជាគម្រោងបែបការបន្សាំ ឬការកាត់បន្ថយ នៃការប្រែប្រួលអាកាសធាតុ ។

លើសពីនេះទៅទៀត លក្ខខណ្ឌផ្សេងៗ រួមមាន ទម្រង់ បែបបទ របស់សំណើ ទាំងទស្សនៈទាន និងគម្រោងសំណើពេញលេញ ត្រូវតែយោងទៅតាមលក្ខខណ្ឌដែលបានចែងក្នុងគោលការណ៍ណែនាំរបស់យើង ។ អ្នកដាក់សំណើ អាចរកព័ត៌មាន និងទម្រង់បែបបទដែលពាក់ពន្ធ័បានគឺនៅក្នុងគេហទំពររបស់ NCSD https://ncsd.moe.gov.kh/

**សំនួរៈ** តើភាពជាដៃគូប្រភេទណា ដែលចាត់ទុកជាដៃគូអាទិភាពសម្រាប់គម្រោងនេះ?
**ចម្លើយៈ** ប្រសិនបើអ្នកដាក់សំណើ មានភាពស្ទាក់ស្ទើក្នុងការរៀបចំគម្រោងតែឯង គឺអាចរកដៃគូបាន តែនេះមិនមែនជាតម្រូវការចាំបាច់ដែលយើងកំណត់នោះទេ ។ វាជាសេរីភាពក្នុងការជ្រើសរើស ឬ រៀបចំសំណើគម្រោងរបស់ខ្លួន ។ ប៉ុន្តែ វាជាលក្ខខណ្ឌតម្រូវរបស់ម្ចាស់ជំនួយ ដែលស្ថាប័នរកប្រាក់ចំណេញ មិនអាចដាក់សំណើ សុំថវិកា នេះ បានទេ ដូច្នេះវិស័យឯកជន/ក្រុមហ៊ុន គឺចាំបាច់ត្រូវតែរកដៃគូ ជាអង្គភាព/ស្ថាបន័ មិនរកប្រាក់ចំណេញ ក្នុងការរៀបចំសំណើគម្រោងនេះ។ គ្រឹះស្ថានសិក្សា អាចជាអ្នកដឹកនាំ (lead applicant) ឬ អាចសហការជាមួយគ្រឹះស្ថានសិក្សាផ្សេងៗ ជាពិសេសគ្រឹះស្ថានថ្នាក់តំបន់ ឬសកល ក្នុងប្រធានបទ ជាក់លាក់ណាមួយ ។

**សំនួរៈ** តើស្ថាបន័/អង្គភាពមួយ អាចដាក់សំណើគម្រោងបានលើសពីមួយដែរឬទេ?
**ចម្លើយៈ** ជាការពិតណាស់ នេះគឺជាការសម្រេចចិត្ត និងសមត្ថភាពរបស់ស្ថាប័ន/អង្គភាពនោះទេ។ ស្ថាប័ន/អង្គភាពមួយ អាចដាក់សំណើគម្រោងបានលើសពីមួយបាន តែជាបទពិសោធន៍ ស្ថាបន័/អង្គភាពមួយ គួរតែយកចិត្តទុក ក្នុងការរៀបចំសំណើគម្រោងមួយអោយជាក់លាក់ ជាការប្រសើរបំផុត។

**សំនួរៈ** តើ Management Cost និង Operational Cost មានន័យដូចម្តេចខ្លះ តើមានលក្ខខណ្ឌអ្វីខ្លះ? ហើយបុគ្គលិក ដែលគាំទ្រក្នុងគម្រោង តើយើងមានគោលការណ៍យ៉ាងដូចម្តេចដែរ?
**ចម្លើយៈ** Management Cost និង Operational Cost សំដៅលើសំភារៈការិយាល័យ របស់របប្រើប្រាស់តិចតួច និង ការចំណាយចាំបាច់ផ្សេងៗទៀត សម្រាប់ប្រតិបត្តិការគម្រោង ។ ចំពោះបុគ្គលិក ដែលមិនមែនជាក្រុមស្នូលរបស់គម្រោងគឺយើងអាចបែងចែកទៅតាមពេលវេលា (ភាគរយ) ដែលគាត់ចំណាយជាក់ស្តែងជាមួយគម្រោងនេះ។ សម្រាប់គម្រោងនេះ Operation Cost យើងអនុញ្ញាតិរហូតដល់ ២០% នៃទំហំទឹកប្រាក់គម្រោងសរុប អញ្ចឹងយើងអាចដាក់បញ្ចូលនូវការចំណាយរដ្ឋបាល បុគ្គលិក និងសំភារៈផ្សេងៗ។ អ្នកដាក់សំណើអាចធ្វើការបែងចែកការចំណាយទាំងនេះតាមភាពជាក់ស្តែងក្នុងរង្វង់ ២០% នេះ។

**សំនួរៈ** តើយើងត្រូវគណនាបដិភាគមិនមែនជាទឹកប្រាក់ (In Kind) ចេញជាទឹកលុយ ឬការរៀបរាប់ដូចជាការិយាល័យ បុគ្គលិក ។ល។?
**ចម្លើយៈ** រាល់ការចូលរួមបដិភាគក្នុងគម្រោងអាចមានពីររូបភាព ជាទឹកប្រាក់ និង មិនមែនទឹកប្រាក់ (In Kind) ។ ចំពោះការចូលរួមមិនមែនទឹកប្រាក់ អ្នកដាក់សំណើ អាចធ្វើការប៉ាន់ប្រមាណ តាមតំលៃទីផ្សារជាក់ស្តែង ហើយសរុបដាក់បញ្ចូលក្នុងសំណើគម្រោងមុននឹងបញ្ជូនមកកាន់លេខាធិការដ្ឋាន GSSD ។

**សំនួរៈ** តើការដាក់សំណើគម្រោងមក GSSD/CCCA តាមរបៀបណា?
**ចម្លើយៈ** រាល់ឯកសារទស្សនៈទាន ឬសំណើគម្រោងទាំងអស់ តម្រូវឱ្យធ្វើជាពីរ ១) ឯកសាររឹង Hard copy (១ច្បាប់) និង២) ឯកសារទន់ soft copy (១ច្បាប់) ហើយបញ្ជូនមកលេខាធិការដ្ឋាន អោយបានមុនម៉ោង ១៧៖០០ ថ្ងៃទី ២២ ខែមករា ឆ្នាំ២០២០ ។ ចំពោះសំណើជា Soft ត្រូវរៀបចំដាក់ក្នុង ឧបករណ៍ផ្ទុកឯកសារ (USB) ហើយប្រគល់មកលេខាធិការដ្ឋានដូចខាងក្រោម ។ លេខាធិការដ្ឋាន មិនទទួលខុសត្រូវនៅ សំណើគម្រោងណាដែលបញ្ជូនមក តាមរយៈ អ៊ីម៉ែលទេ ។

អាស័យដ្ឋាន ៖ នាយកដ្ឋានប្រែប្រួលអាកាសធាតុ (DCC)នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក.ជ.អ.ច (GSSD), ក្រសួងបរិស្ថាន
**ទូរសព្ទ:** (+៨៥៥) ១២ ៣៩១ ៨៦៩ / ៧៦ ៣៣៣ ៣៧១០
**អ៊ីម៉ែល:** admin@camclimate.org.kh
**គេហទំព័រ** https://ncsd.moe.gov.kh

**សំនួរៈ** ចំពោះថវិកា ៥.០០០ ដុល្លារអាមេរិក តើអ្នកដាក់សំណើអាចទទួលបាននៅពេលណា?
**ចម្លើយៈ** ករណីចាំបាច់ អ្នកដាក់សំណើអាចស្នើថវិកា៥,០០០ដុល្លារអាមេរិក នៅក្នុងផែនការថវិកាឮនៃឯកសារទស្សនៈទាន និងអាចធ្វើការទូទាត់ នៅពេលដែលគម្រោងត្រូវបានអនុមត័ បន្ទាប់ពីភ្ជាប់របាយការណ៍ចំណាយត្រឹមត្រូវ ។ ក្នុងករណីនេះ អ្នកដាក់សំណើ ចាំបាច់ត្រូវមានការអនុញ្ញាតិ ដោយលាយលក្ខ័អក្សរជាមុន ពី GSSD ជាចាំបាច់ ។

**សំនួរៈ** ក្នុងករណីសំណើគម្រោងត្រូវបានអនុមត័ដោយ GSSD តើមាននិតិវីធីបែបណាចំពោះការទិញសម្ភារៈ ឬរបស់របរផ្សេងៗ? តើមានលក្ខខណ្ឌជាពិសេសណាមួយទេ?
**ចម្លើយៈ** ចំពោះគម្រោងដែលនិងត្រូវបានអនុម័ត គឺត្រូវបណ្តុះបណ្តាលពីគោលការណ៍អនុវត្តន៍ជំនួយ (GIG) បន្ទាប់ពីចុះកិច្ចព្រមព្រៀងរួច។ គោលការណ៍នៃការអនុវត្តន៍ យើងមិនមានការហាមឃាត់ ឬកំណត់

ពីប្រភពនៃសម្ភារៈ ឬឧបករណ៍ ឬយានយន្តនោះទេ តែយើងសូមលើកទឹកចិត្តជ្រើសរើស ឬប្រើប្រាស់របស់របរក្នុងស្រុកជាមុន។

**សំនួរៈ** ករណីយើងមានដៃគូសហការនៅក្នុងគម្រោង ឧទាហរណ៍ជាមួយសកលវិទ្យាល័យ មន្ទីរផ្សេងៗ តើយើងត្រូវដាក់ក្នុងទម្រង់សំណើគម្រោងនេះយ៉ាងដូចម្ដេច?
**ចម្លើយៈ** ក្នុងករណីនេះ យើងត្រូវបំពេញឈ្មោះអង្គភាព/ស្ថាបន័ណាដែលជាអ្នកដឹកនាំគម្រោង (Lead applicant) ក្នុងទម្រង់ដាក់ពាក្យ ហើយត្រូវមានការបញ្ជាក់/លិខិតគាំទ្រពីស្ថាបន័/អង្គភាព/មន្ទីរណាមួយដែលជាដៃគូ ភ្ជាប់មកជាមួយ ពេលដាក់សំណើគម្រោង មកអគ្គលេខាធិការដ្ឋានGSSD។

**សំនួរៈ** ចំពោះករណីជួលក្រុមហ៊ុនសវនករ (Audit Firm) តើវាស្ថិតនៅក្នុងទំហំទឹកប្រាក់២០% (Operation Cost)នេះឬទេ? ហើយនិតិវិធីជ្រើសរើសយ៉ាងដូចម្ដេចដែរ?
**ចម្លើយៈ** ការធ្វើសវនកម្ម គឺជាតំរូវការសម្រាប់គម្រោងនេះតែម្ដង ហើយ ត្រូវធ្វើឡើងតែមួយដងទេ ក្នុងវដ្ដគម្រោងទាំងមូល ។ ការធ្វើសវនកម្ម និងត្រូវធ្វើឡើងនៅពេលបញ្ចប់គម្រោង ដោយក្រុមហ៊ុនឯករាជ្យណាមួយ ដែលជាការជ្រើសរើសដោយគម្រោងផ្ទាល់។ សម្រាប់ថវិកាចំណាយ យើងអាចលើកឡើងក្រៅពីទំហំទឹកប្រាក់២០%(Operation Cost)។

**សំនួរៈ** តើការរៀបចំបង្កើតផែនការត្រួតពិនិត្យ វាយតំលៃ នេះធ្វើឡើងនៅពេលណា? តើវាមានទំរង់បែបណា?
**ចម្លើយៈ** ការរៀបចំផែនការត្រួតពិនិត្យ វាយតំលៃជាឯកសារសំខាន់មួយដែលមិនអាចខ្វះបានទាំងពេលដែលរៀបចំឯកសារទស្សនៈទាន និងសំណើគម្រោងពេញលេញ ។ អ្វីដែលខុសគ្នាគឺថា អ្នកដាក់សំណើគ្រាន់តែរៀបចំជាផែនការជាគោលៗ ធំៗ សម្រាប់ការងារត្រួតពិនិត្យវាយតំលៃនេះ ថាតើយើងនឹងធ្វើអ្វីខ្លះ? ធ្វើនៅពេលណា? ដោយនរណាគេ? ដាក់ភ្ជាប់ជាមួយឯកសារទស្សនៈទាន ។ នៅពេលដែលទស្សនៈទាននេះ ត្រូវបានអនុមត័ជាគោលការណ៍សម្រាប់រៀបចំសំណើគម្រោងពេញលេញ ផែនការត្រួតពិនិត្យ និងវាយតំលៃនេះ តំរូវអោយមានការរៀបចំយ៉ាងលំអិតជាងមុន ដូចមាននៅក្នុងទំរង់ឯកសារដែលមានស្រាប់ ។

**សំនួរៈ** ខណៈពេលដែលរយៈពេលគម្រោងនេះ ខ្លី ហើយទំហំថវិកាមានចន្លោះពី៥០ 000 ទៅ ១០០ ០០០ ដុល្លារអាមេរិក តើលក្ខខណ្ឌមួយចំនួនអាចលើកលែងបានទេ? ឧទាហរណ៍ សិក្ខាសាលាបើក/បញ្ចប់គម្រោង សវនកម្ម ការសិក្សាទិន្នន័យមុនការអនុវត្តន៍ និងវាយតំលៃបញ្ចប់គម្រោង។ល។

**ចម្លើយ:** នេះគ្រាន់តែជាលក្ខខណ្ឌអប្បបរិមា និងដើម្បីជានាពីតម្លាភាព និងគណនេយ្យភាពចំពោះការប្រើប្រាស់ថវិការរបស់ម្ចាស់ជំនួយ ។ ជាបទពិសោធន៍កន្លងមក អ្នកដាក់សំណើគម្រោង អាចមានភាពបទបែនទៅតាមទំហំថវិកាដែលបានអនុម័ត ដូចជាសិក្ខាសាលាបើក/បញ្ចប់គម្រោងយើងអាចរៀបចំក្នុងលក្ខខណ្ឌមួយដែលក្រុមគោលដៅ ឫអ្នកពាក់ពន្ធ័បានចូលរួម ដឹងលឺ ពេញលេញ.....រីឯការរៀបចំរបាយការណ៍សកម្មភាព និងហរិញ្ញវត្ថុ ជាត្រីមាស គឺអ្នកដាក់សំណើ គ្រាន់តែបំពេញព័ត៌មានក្នុងទម្រង់ ដែលមានស្រាប់សាមញ្ញា ខ្លី ងាយស្រួល ។ កន្លងមក យើងមានការលំបាកក្នុងការជួយអន្តរគមន៏ ខណៈពេលដែលបញ្ហាដែលកើតមាននៅក្នុងគម្រោង ហើយយើងមិនបានដឹង ឫចុះអន្តរគមន៍ទាន់ពេលវេលា។